**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋបាលខេត្តកំពង់ស្ពឺ**
លេខៈ១៨៥/១៧.សជណ/ផអ៣

កំពង់ស្ពឺ ថ្ងៃទី១៤.....ខែកញ្ញា ឆ្នាំ២០១៧

# សេចក្តីជូនដំណឹង

## ស្តីពី

## ការជ្រើសរើសមន្ត្រីព័ត៌មានវិទ្យាថ្នាក់ខេត្ត ប្រចាំខេត្តកំពង់ស្ពឺ
## (ការជ្រើសរើសលើកទី២)

ផែនការអនុវត្តដំណាក់កាលទី១ (២០១១-២០១៤) ផ្តោតការយកចិត្តទុកដាក់ទៅលើការពង្រឹង និងការអភិវឌ្ឍសមត្ថភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ជាពិសេសរដ្ឋបាលក្រុង ស្រុកឲ្យក្លាយជាស្ថាប័នអភិបាលកិច្ចមូលដ្ឋាន និងអភិវឌ្ឍន៍មូលដ្ឋានយ៉ាងពិតប្រាកដ។ មូលដ្ឋានគ្រឹះសំខាន់ៗ ដូចជារចនាសម្ព័ន្ធ នីតិវិធី ប្រព័ន្ធ និងឧបករណ៍ជាច្រើនសម្រាប់ការបំពេញការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបានរៀបចំឡើងវិញ និងបានផ្តល់ជាបង្អែកយ៉ាងរឹងមាំសម្រាប់ការបោះជំហានឆ្ពោះទៅមុខ។ ទាំងនេះបណ្តាលឲ្យផអ៣ទី១ ក្លាយជាកម្លាំងចលករមួយដ៏សំខាន់សម្រាប់ការងារកំណែទម្រង់ និងជាសនិទានកម្មដ៏សំខាន់ ដែលនាំឲ្យរាជរដ្ឋាភិបាលតាមរយៈកិច្ចប្រជុំលើកទី១០របស់គ.ជ.អ.ប កាលពីខែធ្នូ ឆ្នាំ២០១៤ បានសម្រេចចិត្តអនុវត្តដំណាក់កាលទី២ (ផអ៣ទី២) ដែលចាប់ផ្តើមពីឆ្នាំ២០១៥ ដល់ឆ្នាំ២០១៧។

ចក្ខុវិស័យសម្រាប់ធនធានមនុស្សនៅរដ្ឋបាលថ្នាក់ក្រោមជាតិ គឺការប្រើប្រាស់ធនធានទាំងអស់ដែលមានរួមទាំងមន្ត្រីរាជការស៊ីវិល បុគ្គលិកកិច្ចសន្យា ទាំងផ្នែកឯកជន និងអង្គការសង្គមស៊ីវិល។ ការបង្កើតមណ្ឌលអភិវឌ្ឍន៍ធនធានមនុស្សនៅរាជធានី ខេត្តគឺជាយន្តការថ្មីមួយទៀតនៃផអ៣ទី២ ដែលសង្ឃឹមថានឹងធានាបាននូវការរៀបចំវិធីសាស្ត្រ នៃការអភិវឌ្ឍសមត្ថភាពដែលមានលក្ខណៈឆ្លើយតប និងប្រកបដោយការផ្តួចផ្តើម សំដៅសម្រេចបានដោយជោគជ័យដ៏គ្រប់គ្រាន់ក្នុងការអភិវឌ្ឍសមត្ថភាពនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។

ការអភិវឌ្ឍសមត្ថភាពដល់មន្ត្រីរាជការនឹងត្រូវបន្តពង្រឹងតាមរយៈទីប្រឹក្សានៅថ្នាក់ជាតិ និងនៅថ្នាក់ ៧.

ក្រោមជាតិ។ ជាលទ្ធផលនៃការអភិវឌ្ឍសមត្ថភាពគេសង្ឃឹមថា ជំនួយបច្ចេកទេសនឹងត្រូវបានបន្ថយជាបណ្ដើរៗ ឬជំនួយបច្ចេកទេសទាំងនេះត្រូវបានបង្វែរពីថ្នាក់រាជធានី ខេត្ត ទៅថ្នាក់ក្រុង ស្រុកជាពិសេសគឺត្រូវធ្វើការផ្លាស់ប្ដូរនូវទម្លាប់ និងឥរិយាបថ នៃការប្រើប្រាស់ជំនួយបច្ចេកទេស ដែលទីប្រឹក្សាតែងតែបំពេញការងារជំនួសមន្ត្រីរាជការ ទៅជាបែបផែនដែលទីប្រឹក្សាត្រូវផ្ដោតតែទៅលើការអភិវឌ្ឍសមត្ថភាពដល់មន្ត្រីរាជការ។ ដូចនេះបុគ្គលិកកិច្ចសន្យា ទីប្រឹក្សាដែលស្ថិតនៅក្នុងក្របខណ្ឌផអពទី២ ចាំបាច់ត្រូវផ្ដោតការយកចិត្តទុកដាក់ទៅលើការសម្របសម្រួល និងការផ្ដល់កិច្ចអន្តរាគមន៍ផ្នែកអភិវឌ្ឍន៍សមត្ថភាពឲ្យបានច្រើនជាងមុន ប្រកបដោយគុណភាព និងភាពសក្តិសិទ្ធជាជាងទម្លាប់នៃការធ្វើជំនួស។

ដើម្បីជំនះបាននូវបញ្ហាប្រឈមគួរឲ្យព្រួយបារម្ភដែលអធិប្បាយខាងលើ ទីប្រឹក្សា និងបុគ្គលិកកិច្ចសន្យានៅតាមរដ្ឋបាលថ្នាក់ក្រោមជាតិនានា ដែលក្នុងនោះរួមទាំងបុគ្គលិកគាំទ្របច្ចេកទេសក្រុងស្រុកនឹងត្រូវជ្រើសរើស និងចាត់តាំងឲ្យទៅបម្រើការងារយ៉ាងជិតស្និទ្ធជាមួយក្រុមប្រឹក្សា គណៈអភិបាល និងការិយាល័យនានារបស់រដ្ឋបាលខេត្ត ក្រុង ស្រុក ដើម្បីអភិវឌ្ឍន៍សមត្ថភាពក្នុងការបំពេញអណត្តិរបស់ខ្លួន។

អាស្រ័យហេតុនេះ រដ្ឋបាលខេត្តកំពង់ស្ពឺ សូមប្រកាសជ្រើសរើសបេក្ខជន បេក្ខនារី សម្រាប់មុខតំណែងដូចខាងក្រោម៖

| មុខតំណែង | ចំនួន | ទីកន្លែងបំពេញការងារ |
|---|---|---|
| មន្ត្រីព័ត៌មានវិទ្យា ថ្នាក់ខេត្ត | ០១នាក់ | សាលាខេត្តកំពង់ស្ពឺ |

តួនាទី និងភារកិច្ចទទួលខុសត្រូវលម្អិត (TOR) និងតម្រូវការគុណសម្បត្តិសម្រាប់មុខតំណែងខាងលើ ព្រមទាំងពាក្យសុំបម្រើការងាររបស់លេខាធិការដ្ឋានគ.ជ.អ.ប អាចរកបាននៅសាលាខេត្ត និងមាននៅលើគេហទំព័ររបស់គ.ជ.អ.ប *(http://www.ncdd.gov.kh /procurementjobs)* និងមានបិទផ្សាយនៅលើក្ដារព័ត៌មានសាលាខេត្ត ក្រុង ស្រុក អង្គការសង្គមស៊ីវិល និងមន្ទីរពាក់ព័ន្ធនានាជុំវិញ ខេត្ត រួមទាំងសាលាឃុំ សង្កាត់ផងដែរ។

បេក្ខជន បេក្ខនារីដែលមានចំណាប់អារម្មណ៍ សូមធ្វើលិខិតដាក់ពាក្យសុំ និងប្រវត្តិរូបសង្ខេប (រាប់បញ្ចូលទាំងពាក្យសុំបម្រើការងាររបស់គ.ជ.អ.ប) ដោយមានបញ្ជាក់ព័ត៌មានសម្រាប់ទំនាក់ទំនង (រួមមាន៖ អាសយដ្ឋាន លេខទូរស័ព្ទ ឬអ៊ីម៉ែល) មកកាន់ផ្នែកគ្រប់គ្រងបុគ្គលិកនៃទីចាត់ការគ្រប់គ្រងធនធានមនុស្សរបស់សាលាខេត្តកំពង់ស្ពឺនៅគ្រប់ម៉ោងធ្វើការ ឬតាមរយៈលោក ពៅ ប៊ុនធឿន ដែលមានលេខទូរស័ព្ទ 097 86 21 855 /012 59 72 01 ឬសារអេឡិចត្រូនិច *bunthoeurn.peou@ksp.ncdd.gov.kh*។

**ស្ត្រីត្រូវបានលើកទឹកចិត្តក្នុងការដាក់ពាក្យសម្រាប់មុខតំណែងនេះ**

ថ្ងៃឈប់ទទួលពាក្យៈ ថ្ងៃទី០២ ខែតុលា ឆ្នាំ២០១៧ ត្រឹមម៉ោង១៧ និង៣០នាទី ល្ងាច។ មានតែបេក្ខជនដែលមានឈ្មោះក្នុងបញ្ជីសម្រាំងបេក្ខជនអាទិភាព (shortlist) ប៉ុណ្ណោះ ដែលនឹងទទួលបានព័ត៌មានអំពីការប្រឡងជ្រើសរើស។

<u>បញ្ជាក់៖</u> មុខតំណែងនេះ ជាប្រភេទកិច្ចសន្យា ដូច្នេះបេក្ខជនដែលនឹងត្រូវជ្រើសរើសឲ្យបំពេញការងារត្រូវតែមិនមែនជាមន្ត្រីរាជការស៊ីវិល។ ក្នុងករណីដែលបេក្ខជនជាមន្ត្រីរាជការស៊ីវិល បេក្ខជននោះ ត្រូវដាក់ពាក្យសុំស្ថិតនៅក្នុងភាពទំនេរគ្មានប្រាក់បៀវត្សក្នុងរយៈពេល នៃការបំពេញការងារជាមួយកម្មវិធីជាតិ។

**ត.ប អភិបាលខេត្ត**

**នាយករដ្ឋបាល**

**ភខ.វណ្ណារ៉ូ**